# ស្ថាប័នប្រឆាំងអំពើពុករលួយអាស៊ានដឹងបើកកិច្ចប្រជុំលេខាធិការដ្ឋានលើកទី១៧ តាមរយៈសន្និសីទវីដេអូ

**ភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១**




**ឯកឧត្តម បណ្ឌិត អ៊ិន បញ្ញា** តំណាងអង្គភាពប្រឆាំងអំពើពុករលួយ (អ.ប.ព.) នឹងចូលរួមក្នុងកិច្ចប្រជុំលេខាធិការដ្ឋានលើកទី ១៧ នៃស្ថាប័នប្រឆាំងអំពើពុករលួយអាស៊ាន ឬហៅកាត់ថាអាស៊ានផេក ASEAN-PAC (ASEAN Parties Against Corruption) ដែលភាគីវៀតណាមជាម្ចាស់ផ្ទះនិងដឹកនាំកិច្ចប្រជុំតាមរយៈសន្និសីទវីដេអូ នឹងប្រព្រឹត្តទៅនៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០២១ ។

កិច្ចប្រជុំលេខាធិការដ្ឋានអាស៊ានផេកជាវេទិកាសម្រាប់សមាជិកប្រទេសនីមួយៗក្នុងអាស៊ានបន្តពិភាក្សាទៅលើបញ្ហាពាក់ព័ន្ធជាមួយនឹងដំណើការប្រព្រឹត្តទៅរបស់អាស៊ានផេក និងរបៀបវារៈសំខាន់ៗសម្រាប់ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំអាស៊ានផេកលើកទី ១៧ ដែលភាគីប្រ៊ុយណេនឹងធ្វើជាម្ចាស់ផ្ទះនៅចុងឆ្នាំ ២០២១ នេះ ។ បន្តភ្ជាប់ពីកិច្ចប្រជុំនេះ គណៈប្រតិភូ អ.ប.ព. កម្ពុជា ក៏នឹងចូលរួមក្នុងសិក្ខាសាលាថ្នាក់តំបន់ដែលរៀបចំឡើងក្រោមកិច្ចសហការរវាងភាគីម្ចាស់ផ្ទះ និងការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) ផងដែរ ។

ភាគី អ.ប.ព. កម្ពុជា ចូលរួមក្នុងកិច្ចប្រជុំនេះរួមមាន **ឯកឧត្តម បណ្ឌិត អ៊ិន បញ្ញា** ឧបការី **លោក ទូច ខេមរិទ្ធ** អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ពាក្យប្តឹង និងអន្តរជាតិ **លោក ញឹវ បញ្ញារិទ្ធ** អនុប្រធាននាយកដ្ឋានប្រកាសទ្រព្យសម្បត្តិ និងបំណុល **លោក អ៊ីឡារិទ្ធ** អនុប្រធាននាយកដ្ឋានប្រកាសទ្រព្យសម្បត្តិ និងបំណុល **លោក យ៉ា វង្សី** ប្រធានការិយាល័យអន្តរជាតិ **លោកស្រី នៅ វត្តី** អនុប្រធានការិយាល័យអន្តរជាតិ **លោក ឡុង វិច្ឆិកា** អនុប្រធានការិយាល័យអន្តរជាតិ និងមន្ត្រីនៃការិយាល័យអន្តរជាតិមួយចំនួន ។

សូមរំលឹកដែរថាអាស៊ានផេក (ASEAN-PAC) ដែលពីមុនមានឈ្មោះថាស៊ីផេក (SEA-PAC) ត្រូវបានទទួលស្គាល់ជាអង្គភាពភ្ជាប់ខ្លួនជាមួយអាស៊ាន (Entity Associated with ASEAN) នៅក្នុងឆ្នាំ ២០១៧ នេះហើយបច្ចុប្បន្នមានសមាជិកទាំងអស់ចំនួន ១០ គឺ អាស៊ាន ១០ ប្រទេស ៕